# “ប្រែចិត្ត...ដើម្បីយើងអាចប្រោសអ្នកឱ្យបានជា”

អែលឌើរ នែល អិល អាន់ឌើរសិន
នៃក្រុមនៃពួកសាវក 12 នាក់

*ការអញ្ជើញឱ្យប្រែចិត្ត គឺពុំមែនសុទ្ធតែជាសម្លេងនៃការផ្ចាញ់ផ្ចាលទាំងអស់នោះទេ ផ្ទុយទៅវិញ វាក៏ជាការអំពាវនាវមួយដោយក្តីស្រឡាញ់ ឱ្យត្រឡប់ថយក្រោយវិញ ហើយ “ឆ្ពោះសំដៅ” ទៅរកព្រះផងដែរ ។*

បងប្អូនប្រុសស្រីទាំងឡាយរបស់ខ្ញុំ ចាប់តាំងពីការហៅរបស់ខ្ញុំចូលទៅក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ គឺមានរយៈពេលប្រាំមួយខែហើយ ។ វានៅតែជាបទពិសោធន៍ដ៏រាបសា ដើម្បីបំរើជាមួយនឹងពួកបុរសដែលបានធ្វើជាគំរូ និងជាគ្រូបង្រៀនរបស់ខ្ញុំជាយូរយាណាស់មកហើយ ។ ខ្ញុំមានការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការអធិស្ឋាន និងការបោះឆ្នោតគាំទ្ររបស់អ្នក ។ ចំពោះរូបខ្ញុំនេះគឺជាពេលមួយនៃការអធិស្ឋានដ៏ក្លៀវក្លា ដើម្បីស្វែងរកដោយស្មោះស្ម័គ្រនូវការទទួលយកពីព្រះអម្ចាស់ ។ ខ្ញុំទទួលអារម្មណ៍នូវសេចក្តីស្រឡាញ់របស់ទ្រង់ ជារបៀបដ៏ពិសិដ្ឋ ហើយមិនអាចបំភ្លេចបានឡើយ ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា ទ្រង់មានព្រះជន្មរស់ ហើយថានេះ គឺជាកិច្ចការដ៏បរិសុទ្ធរបស់ទ្រង់ ។

យើងស្រឡាញ់ប្រធាន ថូម៉ាស អេស ម៉នសុន ជាព្យាការីរបស់ព្រះអម្ចាស់ ។ ខ្ញុំនឹងចាំទុកពីសណ្តានចិត្តរបស់លោកជានិច្ចកាលដែលលោកបានផ្តល់ការហៅមួយដល់ខ្ញុំ កាលពីខែ មេសា ។ នៅចុងបញ្ចប់នៃការសម្ភាសន៍របស់យើង នោះលោកបានលើកដៃរបស់លោកមកឱបខ្ញុំ ។ ប្រធាន ម៉នសុន ជាបុរសដែលមានរាងខ្ពស់ ។ នៅពេលលោកបានប្រើដៃដ៏វែងរបស់លោកមកឱបខ្ញុំ នោះខ្ញុំមានអារម្មណ៍ថា ខ្លួនឯងដូចជាក្មេងប្រុសតូចម្នាក់ ដែលកំពុងបីថ្នាក់ថ្នមនៅក្នុងរង្វង់ដៃដ៏កក់ក្តៅរបស់ឪពុកជាទីស្រឡាញ់ម្នាក់ ។

ប៉ុន្មានខែក្រោយមក បន្ទាប់ពីបទពិសោធន៍នោះ ខ្ញុំបានគិតពិចារណាពីការអញ្ជើញរបស់ព្រះអម្ចាស់ឱ្យមករកទ្រង់ និងដើម្បីទទួលបានការឱបខាងវិញ្ញាណនៅក្នុងព្រះហស្តរបស់ទ្រង់ ។ ទ្រង់បានមានព្រោះបន្ទូលថា “មើលចុះ [ដៃ] នៃសេចក្តីមេត្តាករុណារបស់យើងសន្ធឹងទៅរកអ្នក ហើយអស់អ្នកណាដែលមក អ្នកនោះហើយដែលយើងនឹងទទួល ហើយមានពរហើយដល់អ្នកណាដែលមករកយើង” ។[1]

ព្រះគម្ពីរបានលើកឡើងពីការលាត[2] ការហុច[3] ការលើក[4] និងការឱបក្រសោប[5]នៃព្រះហស្តរបស់ទ្រង់ ។ កាយវិការទាំងនេះត្រូវបានគេពិពណ៌នាថា ជាភាពខ្លាំងក្លា[6] និងបរិសុទ្ធ[7] ព្រះពាហុនៃសេចក្តីមេត្តាករុណា[8] ដៃនៃសេចក្តីសុខ[9] ពាហុនៃសេចក្តី-ស្រឡាញ់[10] ដែលបាន “លូករាល់ៗថ្ងៃ” ។[11]

យើងម្នាក់ៗបានទទួលអារម្មណ៍នូវដៃខាងវិញ្ញាណផ្សេងទៀតដែលមាននៅជុំវិញយើង ។ យើងទទួលអារម្មណ៍ពីការអភ័យទោស សេចក្តីស្រឡាញ់ និងការលួងលោមរបស់ទ្រង់ ។ ព្រះអម្ចាស់ទ្រង់បានមានបន្ទូលថា “យើងជា[អ្នក]ដែលកំសាន្តចិត្តអ្នករាល់គ្នា” ។[12]

ជាញឹកញាប់ កាលដែលព្រះអម្ចាស់មានព្រះរាជបំណងចង់ឱ្យយើងមករកទ្រង់ ហើយត្រូវបានឱបក្រសោបនៅក្នុងព្រះពាហុរបស់ទ្រង់ នោះគឺជាការអញ្ជើញមួយឱ្យមានការប្រែចិត្ត ។ "មើលចុះ ទ្រង់បានអញ្ជើញមនុស្សលោកទាំងអស់ ត្បិតព្រះពាហុ នៃសេចក្ដី-មេត្តាករុណាបានលាតសន្ធឹងមករកគេ ហើយទ្រង់មានព្រះបន្ទូលថា : ចូរប្រែចិត្តចុះ នោះយើងនឹងទទួលអ្នក" ។[13]
នៅពេលយើងធ្វើអំពើបាប នោះយើងបានងាកចេញពីឆ្ងាយពីព្រះ ។ នៅពេលយើងប្រែចិត្តយើងត្រឡប់មករកព្រះ ។

ការអញ្ជើញឱ្យមានការប្រែចិត្ត គឺពុំមែនសុទ្ធតែជាសម្លេងនៃការផ្ចាញ់ផ្ចាលទាំងអស់នោះទេ ផ្ទុយទៅវិញ វាក៏ជាការអំពាវនាវមួយដោយក្ដីស្រឡាញ់ឱ្យត្រឡប់ថយក្រោយវិញ ហើយ"ឆ្ពោះសំដៅ"ទៅរកព្រះផងដែរ ។[14] ការអញ្ជើញនេះ គឺជាការបក់ព្រះហស្ត ដង្ហោយហៅរបស់ព្រះវរបិតាជាទីស្រឡាញ់ និងព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ ដើម្បីធ្វើឱ្យយើងក្លាយជាមនុស្សល្អ ដើម្បីឈោងចាប់ផ្លូវដ៏ខ្ពស់មួយនៃជីវិត ដើម្បីកែប្រែ និងទទួលអារម្មណ៍នូវសុភមង្គលដែលកើតមកពីការគោរពតាមព្រះបញ្ញត្តិ ។ ការធ្វើជាសិស្សព្រះគ្រីស្ទ យើងរីករាយចំពោះពរជ័យនៃការប្រែចិត្ត និងសេចក្ដីអំណរនៃការអភ័យទោសឱ្យ ។ ការរីករាយនេះបានក្លាយទៅជាផ្នែកមួយនៃជីវិតរបស់យើង ដោយការរៀបចំនូវរបៀបដែលយើងគិត និងទទួលអារម្មណ៍ ។

នៅក្នុងចំណោមមនុស្សមួយម៉ឺននាក់ ដែលកំពុងស្ដាប់សន្និសីទនេះ គឺមានកំរិតនៃភាពសក្ដិសម និងសេចក្ដីសុចរិតផ្ទាល់ខ្លួនខុសប្លែកពីគ្នា ។ ប៉ុន្តែ ការប្រែចិត្តគឺជាពរជ័យមួយសំរាប់យើងគ្រប់គ្នា ។ យើងម្នាក់ៗត្រូវការទទួលអារម្មណ៍នូវព្រះពាហុនៃសេចក្ដីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ តាមរយៈការអភ័យទោសចំពោះអំពើបាបរបស់យើង ។

ច្រើនឆ្នាំកន្លងទៅ ខ្ញុំត្រូវបានសុំឱ្យជួបជាមួយនឹងបុរសម្នាក់ដែលកាលពីមុនធ្លាប់រស់នៅក្នុងស្ថានភាពមិនសុចរិតមួយ ។ ជាលទ្ធផលនៃការជ្រើសរើសខុសរបស់គាត់ នោះគាត់បានបាត់បង់សមាជិកភាពនៅក្នុងសាសនាចក្ររបស់ខ្លួន ។ ជាច្រើនឆ្នាំហើយ ចាប់តាំងពីគាត់បានត្រឡប់មកសាសនាចក្រវិញ និងបានគោរពតាមព្រះបញ្ញត្តិដោយស្មោះត្រង់នោះ ប៉ុន្តែទង្វើររបស់គាត់កាលពីមុននៅតែតាមបន្ទាចគាត់ជានិច្ច ។ នៅក្នុងការជួបជាមួយនឹងគាត់ ខ្ញុំបានទទួលអារម្មណ៍ នូវការអៀនខ្មាស់ និងវិប្បដិសារីដ៏ជ្រាលជ្រៅរបស់គាត់ ដោយបានផ្ដាច់សេចក្ដីសញ្ញារបស់ខ្លួនអស់មួយរយៈមកនោះ ។ បន្ទាប់ពី ការសម្ភាសន៍របស់យើង ខ្ញុំបានដាក់ដៃរបស់ខ្ញុំលើក្បាលរបស់គាត់ ដើម្បីធ្វើការប្រសិទ្ធពរបព្វជិតភាពដល់គាត់ ។ ពីមុនចាប់ផ្ដើមនិយាយ ខ្ញុំបានទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់ និងការអភ័យទោសរបស់ព្រះអង្គសង្គ្រោះចំពោះគាត់ ។ បន្ទាប់ពីការប្រសិទ្ធពរ យើងបានឱបគ្នាទៅវិញទៅមក ហើយបុរសម្នាក់នោះបានយំ ។

ខ្ញុំស្ញប់ស្ញែងចំពោះការឱបក្រសោបរបស់ព្រះអង្គសង្គ្រោះដោយព្រះពាហុនៃសេចក្ដីមេត្តាករុណា និងសេចក្ដីស្រឡាញ់ចំពោះអ្នកប្រែចិត្ត មិនថាអំពើបាបដែលត្រូវបានលះបង់នោះមានភាពអត្មានិយមបែបណានោះឡើយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះអាចមានលទ្ធភាព ហើយមានព្រះទ័យចង់អភ័យទោសដល់អំពើបាបរបស់យើង ។ លើកលែងតែមនុស្សមួយចំនួនដែលជ្រើសយកស្ថាននរក បន្ទាប់ពីបានស្គាល់នូវភាពពោរពេញមួយប៉ុណ្ណោះ គឺគ្មានអំពើបាបណាមួយដែលមិនអាចទទួលបានការអភ័យទោសឡើយ ។[15] វាគឺជាឱកាសដ៏អស្ចារ្យអ្វីម្លេះទេ សំរាប់យើងម្នាក់ៗដើម្បីងាកចេញពីអំពើបាបរបស់យើង ហើយមករកព្រះគ្រីស្ទនោះ ។ ការអភ័យទោសដ៏ទេវភាព គឺជាផលផ្លែដ៏ផ្អែមបំផុតមួយនៃដំណឹងល្អ ដោយដកយកកំហុស និងការឈឺចាប់

ចេញពីដួងចិត្តរបស់យើង ហើយជំនួសមកវិញនូវសេចក្តីអំណរ និងសេចក្តីសុខសាន្តនៅក្នុងមនសិការ។ ព្រះយេស៊ូវបានប្រកាសថា "តើអ្នករាល់គ្នាមិនចង់ត្រឡប់មករកយើង ហើយប្រែចិត្តពីអំពើបាបទាំងឡាយរបស់អ្នក ហើយប្រែចិត្តជឿ ដើម្បីយើងអាចប្រោសអ្នកឱ្យបានជាទេឬ?" ។[16]
មានអ្នកស្តាប់មួយចំនួននៅថ្ងៃនេះអាចនឹងត្រូវការនូវ "ការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្ត"[17] ដើម្បីប្រឈមមុខនឹងអំពើបាបដ៏ធ្ងន់ធ្ងរទាំងឡាយ។ ជំនួយរបស់ពួកអ្នកដឹកនាំបព្វជិតភាពប្រហែលជារឿងមួយដ៏ចាំបាច់។ ជាងនេះទៀត ការប្រែចិត្ត គឺជារឿងផ្ទាល់ខ្លួនដោយស្វែងរកជំនួយរបស់ព្រះអម្ចាស់ជាប្រចាំ ដើម្បីធ្វើការផ្លាស់ប្តូរដែលចាំបាច់។

ភាគច្រើន ការប្រែចិត្តគឺជាដំណើរមួយ ច្រើនជាងព្រឹត្តិការទាន់ពេលមួយ។ វាមិនងាយស្រួលទេ។ ការផ្លាស់ប្តូរ គឺមានការលំបាក។ វាតំរូវឱ្យមានការរត់ចូលនៅក្នុងខ្យល់ និងការហែលបញ្ច្រាស់ទឹក។ ព្រះយេស៊ូវបានមានបន្ទូលថា "បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឱ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ" ។[18] ការប្រែចិត្ត គឺជាការងាកចេញពីរឿងមួយចំនួនមានដូចជា ការមិនស្មោះត្រង់ អំនួត កំហឹង និងគំនិតមិនបរិសុទ្ធ ហើយងាកឆ្ពោះទៅរករឿងផ្សេងវិញ ដូចជា ចិត្តល្អមិនអាត្មានិយម អត់ធ្មត់ និងជីវភាពខាងវិញ្ញាណ។ វាគឺជា "ការងាកមក"រកព្រះវិញ។

តើយើងសំរេចថាការប្រែចិត្តរបស់យើងគួរផ្តោតសំខាន់ទៅលើផ្នែកណាមួយនោះបានដោយរបៀបណា? នៅពេលមានមនុស្សជាទីស្រឡាញ់ ឬមិត្តភក្តិម្នាក់ណែនាំនូវរឿងមួយចំនួនដែលយើងត្រូវផ្លាស់ប្តូរ នោះមានពេលខ្លះ គំនិតជាមនុស្សខាងសាច់ឈាមរបស់យើងបានផុសឡើង ហើយឆ្លើយតបថា "អ្ហូ អ្នកគិតថាខ្ញុំគួរតែផ្លាស់ប្តូរមែនទេ? អញ្ចឹង ចាំខ្ញុំប្រាប់ពីបញ្ហាមួយចំនួនរបស់អ្នកវិញម្តង"។ ការចាប់ផ្តើមដ៏ប្រសើរមួយ គឺការទូលអង្វរដោយរាបសាដល់ព្រះអម្ចាស់ថា : "ឱ ព្រះវរបិតាអើយ តើទ្រង់សព្វព្រះទ័យឱ្យទូលបង្គំធ្វើអ្វី?" នោះចម្លើយនឹងកើតមានឡើង។ យើងទទួលអារម្មណ៍នូវការផ្លាស់ប្តូរដែលយើងត្រូវធ្វើ។ ព្រះអម្ចាស់មានបន្ទូលប្រាប់យើងទាំងនៅក្នុងគំនិត និងក្នុងដួងចិត្តរបស់យើង។[19]

បន្ទាប់មក យើងត្រូវបានអនុញ្ញាតឱ្យជ្រើសរើសថា: តើយើងនឹងប្រែចិត្ត ឬក៏រារាំងដល់លទ្ធភាពនៃការទទួលពរជ័យមកពីស្ថានសួគ៌ដែរឬទេ?

អាលម៉ាបានព្រមានថា "កុំខិតខំដោះសារខ្លួនដោយនូវចំណុចតូចតាច"[20] ឡើយ នៅពេលយើង "រារាំងដល់លទ្ធភាពនៃការទទួលពរជ័យ" នោះយើងឈប់ជឿលើសម្លេងខាងវិញ្ញាណដែលអញ្ជើញយើងឱ្យផ្លាស់ប្តូរទៀតហើយ។ យើងអធិស្ឋានក៏ពិតមែន ប៉ុន្តែខ្វះការយកចិត្តទុកដាក់ស្តាប់។ ការអធិស្ឋានរបស់យើងខ្វះនូវសេចក្តីជំនឿដែលដឹកនាំទៅរកការប្រែចិត្ត។[21]

នៅពេលនេះ ប្រហែលជាមានមនុស្សម្នាក់នឹងនិយាយថា "បងប្រុស អាន់ឌ៊ើរសិន លោកមិនយល់នោះទេ។ លោកមិនយល់ពីអារម្មណ៍ដែលខ្ញុំមានឡើយ។ គឺវាពិបាកផ្លាស់ប្តូរខ្លាំងណាស់"។

អ្នកនិយាយត្រូវហើយ ខ្ញុំមិនយល់ការណ៍ទាំងអស់នោះទេ។ ប៉ុន្តែ នៅមានព្រះមួយអង្គដែលយល់ពីការណ៍នេះ។ ទ្រង់ជ្រាប។ ទ្រង់យល់ពីការឈឺចាប់របស់អ្នក។ ទ្រង់បានប្រកាសថា : "យើងបានចារិកឯងទុកនៅផ្ទៃបាតដៃរបស់យើងហើយ" ។[22] ព្រះអង្គ

សង្គ្រោះគង់នៅទីនោះកំពុងតែឈោងមករកយើង ហើយបង្គាប់យើងម្នាក់ៗថា: "ចូរមកខ្ញុំចុះ"។[23] យើងអាចប្រែចិត្ត។ យើងអាច!

ដោយដឹងពីកន្លែងដែលយើងត្រូវផ្លាស់ប្តូរ នោះយើងកើតទុក្ខចំពោះភាពសោកសៅដែលយើងបានបណ្តោយឱ្យកើតឡើង។ ការណ៍នេះនាំឱ្យមានការសារភាពដ៏ស្មោះ និងអស់ពីចិត្តចំពោះព្រះអម្ចាស់ និងចំពោះមនុស្សដទៃ បើចាំបាច់។ [24] បើអាចធ្វើទៅបាន នោះយើងធ្វើការសងត្រឡប់ទៅវិញនូវអ្វីដែលយើងបានធ្វើឱ្យខូចខាត ឬយកដោយខុសឆ្គង។

ការប្រែចិត្ត ក្លាយជាផ្នែកមួយនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។ ការទទួលទានសាក្រាម៉ង់របស់យើង ជារៀងរាល់ សប្តាហ៍ គឺសំខាន់ណាស់---ដើម្បីមករកព្រះអម្ចាស់ដោយឱនលំទោន ហើយរាបសានៅចំពោះព្រះភ័ក្ត្រទ្រង់ ដោយទទួលស្គាល់ពីការពឹងផ្អែករបស់យើងទៅលើទ្រង់ ហើយទូលសុំទ្រង់ឱ្យអភ័យទោស និងដើម្បីធ្វើឱ្យយើងជ្រះស្អាតជាថ្មី ហើយសន្យាថានឹងចងចាំទ្រង់ជានិច្ច។

ពេលខ្លះ នៅក្នុងការប្រែចិត្តរបស់យើង និងនៅក្នុងកិច្ចខិតខំប្រចាំថ្ងៃដើម្បីក្លាយខ្លួនដូចជាព្រះគ្រីស្ទ នោះយើងរកឃើញថា ខ្លួនឯងជួបបញ្ហាដដែលៗម្តងហើយម្តងទៀត។ ដូចជាការឡើងលើភ្នំមួយដែលមានដើមឈើ ដោះជុំជិតដែរ ពេលខ្លះយើង មើលមិនឃើញពីការរីកចំរើនរបស់យើងឡើយ រហូតដល់យើងឡើងជិតដល់ទីកំពូល ហើយក្រឡេកមើលមកក្រោយវិញ ពីទីនោះមក។ សូមកុំបាក់ទឹកចិត្ត។ បើអ្នករាល់គ្នាកំពុងព្យាយាម និងខិតខំប្រែចិត្ត នោះអ្នករាល់គ្នាកំពុងស្ថិតនៅក្នុងដំណើរការនៃការប្រែចិត្តហើយ។

នៅពេលយើងមានភាពប្រសើរឡើង នោះយើងនឹងមើលឃើញពីជីវិតកាន់តែច្បាស់ ហើយទទួលអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធកំពុងខិតខំធ្វើការយ៉ាងខ្លាំងនៅក្នុងខ្លួនរបស់យើង។

ពេលខ្លះ យើងមានការងឿងឆ្ងល់ថា តើហេតុអ្វីបានជាយើងនៅចងចាំអំពើបាបរបស់យើង បន្ទាប់ពីយើងបានលះបង់វា។ តើហេតុអ្វីបានជាភាពសោកសៅនៃកំហុសរបស់យើង ពេលខ្លះនៅបន្តកើតមានបន្ទាប់ពីការប្រែចិត្តរបស់យើងយ៉ាងដូច្នេះ?

អ្នករាល់គ្នាប្រហែលជានៅចាំពីដំណើរដ៏ផ្អែមល្ហែមមួយដែលប្រធាន ជេមស៍ អ៊ី ហ្វោស្ត បានលើកឡើង។ "ក្នុងនាមជាក្មេងប្រុសតូចម្នាក់ដែលរស់នៅក្នុងកសិដ្ឋាន... ខ្ញុំនៅចាំថា លោកយាយ របស់ខ្ញុំ...បានធ្វើម្ហូបឱ្យយើង បរិភោគនៅលើចង្ក្រានដាំអូសមួយដ៏ក្តៅ។ នៅពេលធុងដាក់អុសនៅក្បែរចង្ក្រាននោះគ្មានអុស នោះលោកយាយបានលើធុងនោះដោយស្ងាត់ៗ ហើយចេញទៅខាងក្រៅដើម្បីយកអុសដើមសេដាមួយបាច់ដាក់ចូលក្នុងធុងនោះ ហើយយកវាត្រឡប់មកដាក់ក្នុងផ្ទះវិញ"។

នៅពេលនោះ សម្លេងរបស់ប្រធាន ហ្វោស្ត បានលាយឡំនឹងទឹកភ្នែក នៅពេលលោកបន្តមានប្រសាសន៍ថា : "ខ្ញុំដាច់ចិត្តណាស់... ដោយបណ្តោយឱ្យលោកយាយជាទីស្រឡាញ់របស់ខ្ញុំរើសអុសដាក់នៅក្នុងធុងឈើនៅផ្ទះបាយ ឯខ្ញុំបែរជានៅអង្គុយទីនោះទេវិញ។ ខ្ញុំមានអារម្មណ៍ថា ខ្មាស់ខ្លួនឯង ហើយសោកស្តាយពេញមួយជីវិតសំរាប់ [អំពើបាប] នៃការធ្វេសប្រហែសរបស់ខ្ញុំ។ នៅថ្ងៃណាមួយខ្ញុំសង្ឃឹមថា ខ្ញុំនឹងនិយាយសុំទោសពីគាត់"។[25]

ច្រើនជាង 65 ឆ្នាំបានកន្លងផុតទៅហើយ។ បើប្រធាន ហ្វោស្ត នៅចាំ ហើយសោកស្ដាយដោយមិនបានជួយដល់លោកយាយរបស់លោកនៅច្រើនឆ្នាំក្រោយមក តើយើងគួរតែភ្ញាក់ផ្អើលចំពោះរឿងមួយចំនួន ដែលយើងនៅចាំ និងសោកស្ដាយដែរឬទេ? ព្រះគម្ពីរមិនបានលើកឡើងថា យើងនឹងភ្លេចអំពើបាបរបស់យើងនៅក្នុងជីវិតរមែងស្លាប់នេះឡើយ។ ផ្ទុយទៅវិញ ព្រះគម្ពីរបានប្រកាសថា ព្រះអម្ចាស់នឹងបំភ្លេចការណ៍ទាំងនេះ។[26]

ការលះបង់អំពើបាបគឺមានន័យថា ជាការមិនវិលត្រឡប់ទៅធ្វើវាទៀតឡើយ។ ការលះបង់នេះត្រូវការពេលវេលា។ ពេលខ្លះដើម្បីជួយដល់យើង នោះព្រះអម្ចាស់បានអនុញ្ញាតស្រមោលនៃកំហុសនៅជិតជាមក្នុងការចងចាំរបស់យើង។[27] វាគឺជាផ្នែកដ៏សំខាន់មួយនៃការរៀនសូត្រនៅក្នុងជីវិតរមែងស្លាប់របស់យើង។

នៅពេលយើងសារភាពអំពើបាបរបស់យើងដោយស្មោះ ដោយស្ដារនូវអ្វីដែលយើងអាចធ្វើដល់អ្នកដែលបានអាក់អន់ចិត្ត ហើយលះបង់អំពើបាបរបស់យើងដោយការគោរពតាមព្រះបញ្ញត្តិ នោះយើងគឺស្ថិតនៅក្នុងដំណើរការនៃការទទួលបានការអភ័យទោសហើយ។ លុះក្រោយមកទៀត យើងនឹងទទួលអារម្មណ៍ថា ការឈឺចាប់ចំពោះទុក្ខសោករបស់យើងបាន ស្រាកស្រាន្ត ដោយ "ដកយកទោសចេញពីក្នុងចិត្តយើង"[28] ហើយនាំមកនូវ "សេចក្ដីសុខសាន្តក្នុងសតិសម្បជញ្ញៈ"។[29]

ចំពោះពួកអ្នកដែលបានប្រែចិត្តដោយស្មោះ ប៉ុន្តែហាក់ដូចជាពិបាកនៅក្នុងការទទួលបានអារម្មណ៍ស្រាកស្រាន្ត នោះសូមបន្តគោរពតាមព្រះបញ្ញត្តិ។ ខ្ញុំសូមសន្យានឹងអ្នករាល់គ្នាថា ភាពស្រាកស្រាន្តនឹងកើតមាននៅក្នុងកាលវេលារបស់ព្រះអម្ចាស់។ ការព្យាបាលក៏ត្រូវការពេលវេលាផងដែរ។

បើអ្នករាល់គ្នាមានកង្វល់ សូមទៅប្រឹក្សាជាមួយនឹងប៊ីស្សពរបស់អ្នក។ ប៊ីស្សពម្នាក់ គឺមានអំណាចនៃការស្គាល់ខុសត្រូវ។[30] គាត់នឹងជួយដល់អ្នករាល់គ្នា។

ព្រះគម្ពីរបានព្រមានយើងថា : "កុំបង្អង់នូវពេលវេលាចំពោះការប្រែចិត្ត"[31] ប៉ុន្តែនៅក្នុងជីវិតនេះ គឺវាគ្មានការយឺតពេលដើម្បីប្រែចិត្តនោះឡើយ។

មានគ្រាមួយ ខ្ញុំត្រូវបានស្នើសុំឱ្យជួបនឹងស្វាមីភរិយាវ័យចំណាស់មួយគូ ដែលបានចាប់ផ្ដើមត្រឡប់មកកាន់សាសនាចក្រវិញ។ ពួកគាត់ត្រូវបានឪពុកម្ដាយបង្រៀននូវដំណឹងល្អ។ បន្ទាប់ពីអាពាហ៍ពិពាហ៍របស់ពួកគាត់ នោះពួកគាត់បានចាកចេញ ពីសាសនាចក្រនេះ។ ឥឡូវនេះ គឺ 50 ឆ្នាំក្រោយមក ទើបពួកគេបានវិលត្រឡប់មកវិញ។ ខ្ញុំចាំថា បុរសជាស្វាមីបានចូលមកក្នុងការិយាល័យដោយមានដាក់បំពង់អុកស៊ីសែនផង។ ពួកគាត់បានសម្ដែងការសោកស្ដាយ ដោយមិនបានបន្តរស់នៅដោយស្មោះត្រង់។ ខ្ញុំបានប្រាប់ពួកគាត់ពីសុភមង្គលរបស់យើង ដោយសារតែការវិលត្រឡប់មកវិញរបស់ពួកគាត់ ដោយអះអាងដល់ពួកគាត់ពីព្រះពាហុដ៏ស្វាគមន៍របស់ព្រះអម្ចាស់ចំពោះពួកអ្នកដែលប្រែចិត្ត។ បុរសចំណាស់រូបនោះបានតបមកវិញថា "បងប្រុស អាន់ឌើរសិន យើងបាន

ដឹងពីបញ្ហានេះ។ ប៉ុន្តែ ភាពសោកសៅរបស់យើងនោះ គឺថាកូនចៅរបស់យើងពុំមានពរជ័យនៃដំណឹងល្អឡើយ។ យើងបានវិលត្រឡប់មកវិញក៏ពិតមែន ប៉ុន្តែយើងបានមក តែម្នាក់ឯងប៉ុណ្ណោះ"។

ពួកគាត់ពុំមែនមកតែម្នាក់ឯងនោះទេ។ ការប្រែចិត្ត វាមិនគ្រាន់តែផ្លាស់ប្ដូរចំពោះខ្លួនយើងផ្ទាល់នោះទេ ប៉ុន្តែវាក៏ប្រទានដល់ក្រុមគ្រួសាររបស់យើង និងអ្នកដែលយើងស្រឡាញ់ផងដែរ។ ដោយមានទូវការប្រែចិត្តដ៏សុចរិតរបស់យើង ហើយដោយសមស្របតាមពេលវេលារបស់ព្រះអម្ចាស់ នោះព្រះពាហុដែលលាតសន្ធឹងរបស់ព្រះអង្គសង្គ្រោះ នឹងមិនឱបក្រសោបតែយើងម្នាក់ប៉ុណ្ណោះទេ ប៉ុន្តែនឹងលាតសន្ធឹងដល់ជីវិតកូនចៅរបស់យើងផងដែរ។ ជានិច្ចកាល ការប្រែចិត្តមានន័យថា ការមានសុភមង្គលដ៏ធំធេងកំពុងរង់ចាំ។

ខ្ញុំសូមថ្លែងជាសាក្សីថា ព្រះអង្គសង្គ្រោះរបស់យើងអាចជួយឱ្យយើងរួចផុតពីអំពើបាបរបស់យើងបាន។ ខ្ញុំបានទទួលអារម្មណ៍ដោយផ្ទាល់នូវព្រះចេស្ដាដ៏ប្រោសលោះរបស់ទ្រង់។ ខ្ញុំបានមើលឃើញយ៉ាងច្បាស់ ចំពោះព្រះហស្តដែលអាចព្យាបាលបានរបស់ទ្រង់មកលើមនុស្សរាប់ពាន់នាក់ ក្នុងប្រទេសជាតិជាច្រើនជុំវិញពិភពលោក។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា អំណោយដ៏ទេវភាពរបស់ទ្រង់អាចដកយកភាពខ្មាស់អៀនចេញពីដួងចិត្តរបស់យើងបាន ហើយនាំមកនូវសេចក្ដីសុខសាន្តក្នុងគំនិតរបស់យើង។

ទ្រង់ស្រឡាញ់យើង។ យើងគឺជាសមាជិកនៃសាសនាចក្ររបស់ទ្រង់។ ទ្រង់អញ្ជើញឱ្យយើងម្នាក់ៗប្រែចិត្ត ឱ្យងាកចេញពីអំពើបាបរបស់យើង ហើយមករកទ្រង់។ ខ្ញុំសូមជាធ្វើសាក្សីថា ទ្រង់នឹងគង់នៅទីនោះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. នីហ្វៃទី 3 9:14។
2. សូមមើល មរមន 6:17។
3. សូមមើល អាលម៉ា 19:36។
4. សូមមើល ពង្សាវតារក្សត្រទី 2 17:36 ទំនុកដំកើង 136:12។
5. សូមមើល នីហ្វៃទី 2 1:15។
6. សូមមើល គ. និង ស. 123:6។
7. សូមមើល នីហ្វៃទី 3 20:35។
8. សូមមើល អាលម៉ា 5:33។
9. សូមមើល អាលម៉ា 34:16។
10. សូមមើល គ. និង ស. 6:20។
11. នីហ្វៃទី 2 28:32។
12. នីហ្វៃទី 2 8:12។
13. អាលម៉ា 5:33។

14. សូមមើល ហេលេមិន 7:17 ។

15. សូមមើល Boyd K. Packer “The Brilliant Morning of Forgiveness” *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 19 ។

16. នីហ្វៃទី 3 9:13 ។

17. សូមមើល អាលម៉ា 5:12 ។

18. ម៉ាថាយ 16:24 ។

19. សូមមើល គ. និង ស. 8:2 ។

20. អាលម៉ា 42:30 ។

21. សូមមើល អាលម៉ា 34:17--18 ។

22. អេសាយ 49:16 ។

23. នីហ្វៃទី 3 9:14 ។

24. គ. និង ស. 58:43 ។

25. James E. Faust "The Weightier Matters of the Law: Judgment, Mercy, and Faith" *Ensign* ខែ វិច្ឆិកា ឆ្នាំ 1997 ទំព័រ 59 ។

26. សូមមើល គ. និង ស. 58:42--43 សូមមើល អាលម៉ា 36:17--19 ។

27. សូមមើល Dieter F. Uchtdorf "Point of Safe Return" *Ensign* ខែ ឧសភា ឆ្នាំ 2007 ទំព័រ 101 ។

28. អាលម៉ា 24:10 ។

29. ម៉ូសាយ 4:3 ។ បទគម្ពីរនេះបានតភ្ជាប់សុភមង្គលរបស់យើងនៅក្នុងជីវិតនេះ និងនៅជីវិតក្រោយទៅនឹងសេចក្ដីសុខសាន្តនៃសតិសម្បជញ្ញៈ។ សូមកំណត់សំគាល់ពីការបង្រៀនរបស់អាលម៉ាថា ភាពផ្ទុយគ្នានៃសេចក្ដីអំណរ គឺជាការសោកស្ដាយនៃសិតសម្បជញ្ញៈ (សូមមើល អាលម៉ា 29:5)។ ពួកព្យាការីផ្សេងទៀតបានចងភ្ជាប់ការរងទុក្ខរបស់មនុស្សទុច្ចរិតទៅនឹងកំហុសដែលតាមជាប់ពួកគេនៅក្នុងជីវិតនេះ (សូមមើល ម៉ូសា 2:38; 3:24--25; នីហ្វៃទី 2 9:14, 46 មរមន 9:5)។ យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា : "មនុស្សម្នាក់ គឺជាអ្នកធ្វើទារុណកម្ម និងជាអ្នកផ្ដន្ទាទោសដោយខ្លួនឯង។ ហេតុដូច្នេះហើយពួកគេនឹងចូលទៅក្នុងបឹងភ្លើង និងស្ពាន់ធ័រនោះ។ ការឈឺចាប់ចំពោះការខកបំណងនៅក្នុងគំនិតរបស់មនុស្ស គឺមានភាពឆេះឆួលដូចគ្នានឹងបឹងភ្លើង និងស្ពាន់ធ័រដែរ" (យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church,* 6:314)។

30. ម៉ូសាយ 4:3 ។

31. សូមមើល គ. និង ស. 46:27 ។